លទ្ធផលការបោះឆ្នោត

តើចង់ឃើញលទ្ធផលការបោះឆ្នោត នៅពេលវាចូលមកឬទេ? ទទួលព័ត៌មានការរាប់ឆ្នោតរាល់នាទី ក្នុងពេលការបោះឆ្នោត ទូទាំងរដ្ឋ នៅ vote.sos.ca.gov ឬតាម Twitter ដោយតាម @CASOSvote។

ព័ត៌មានសំរាប់អ្នកបោះឆ្នោត មាន 10 ភាសា

មើល www.sos.ca.gov/elections/voting-california ឬទូរស័ព្ទទៅលេខពិសេសអ្នកបោះឆ្នោត ឥតចេញថ្លៃណាមួយនៅខាងក្រោម។

លេខពិសេសអ្នកបោះឆ្នោត	
English	(800) 345-VOTE (8683)
Español / Spanish	(800) 232-VOTA (8682)
中文 / Chinese	(800) 339-2857
हिंदी / Hindi	(888) 345-2692
日本語 / Japanese	(800) 339-2865
ខ្មែរ / Khmer	(888) 345-4917
한국어 / Korean	(866) 575-1558
Tagalog	(800) 339-2957
ไทย / Thai	(855) 345-3933
Việt ngữ / Vietnamese	(800) 339-8163
TTY / TDD	(800) 833-8683



ថ្ងៃទី 7 ខែមិថុនា
ការបោះឆ្នោត
ប្រធានាធិបតីជាបឋម

ថ្ងៃទ 8 ខែវិច្ឆិកា
ការបោះឆ្នោតទូទៅ

កន្លែងបោះឆ្នោតបើក
ម៉ោង **7:00** ព្រឹក
ដល់ **8:00** យប់
នៅថ្ងៃបោះឆ្នោត

បោះឆ្នោត រដ្ឋកាលីហ្វ័រនីញ៉ា
www.sos.ca.gov

California Secretary of State Alex Padilla
(888) 345-4917

Khmer

ចុះឈ្មោះបោះឆ្នោត

ដើម្បីចុះឈ្មោះបោះឆ្នោតក្នុងរដ្ឋកាលីហ្វ័រនីញ៉ាអ្នកត្រូវតែជា :

ពលរដ្ឋនៃសហរដ្ឋអាមេរិក;

អ្នកមូលដ្ឋាននៃរដ្ឋកាលីហ្វ័រនីញ៉ា;

មានអាយុ 18 ឆ្នាំ ឬចាស់ជាង នៅថ្ងៃបោះឆ្នោត;

បច្ចុប្បន្ននេះ មិនបានជាប់ពន្ធនាគារ ឬ ឋិតក្នុងការសាកល្បងខ្លួន សំរាប់ការ ជាប់ទោសឧក្រិដ្ឋ; និង

តុលាការមិនបានរកឃើញថាគ្មានសមត្ថភាពខាងផ្លូវអារម្មណ៍។

អ្នកអាចដាក់ពាក្យសុំតាម អ៊ិនទរ័ណិតនៅ RegisterToVote.ca.gov ឬរកក្រដាសដាក់ពាក្យសុំ នៅការិយាល័យប្រៃសណីយ៍ បណ្ណាល័យ និងការិយាល័យរដ្ឋាភិបាល មួយចំនួន។ នៅក្នុងករណីភាគច្រើន អ្នកត្រូវតែចុះឈ្មោះយ៉ាងតិចបំផុត ចំនួន 15 ថ្ងៃ មុនថ្ងៃបោះឆ្នោត ទើបអាចបោះឆ្នោត ក្នុងការបោះឆ្នោតនោះបាន។

អ្នកត្រូវតែចុះឈ្មោះសាថ្មី ដើម្បីបោះឆ្នោត បើសិនអ្នកផ្លាស់លំនៅ ឬដូរឈ្មោះ ឬការប្រកាន់គណបក្សនយោបាយរបស់អ្នក។

ព័ត៌មានសន្លឹកឆ្នោត

អ្នកបោះឆ្នោតដែលបានចុះឈ្មោះ ទទួលព័ត៌មានណែនាំអ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការ ក្នុងប្រអប់សំបុត្រនៅមួយឬពីរអាទិត្យមុនថ្ងៃបោះឆ្នោត។ ការិយាល័យបោះឆ្នោតខោនធី ផ្ញើកូនសៀវភៅគំរូសន្លឹកឆ្នោតទៅឲ្យអ្នកបោះឆ្នោត។ ព័ត៌មានណែនាំអ្នកឥតនិន្នាការទាំងនេះ រួមមានអំពីវិធីសន្លឹកឆ្នោត បេក្ខជន សិទ្ធិការបោះឆ្នោត និងមានច្រើនទៀត។

បោះឆ្នោតតាមសំបុត្រ

អ្នកបោះឆ្នោតណាម្នាក់ដែលបានចុះឈ្មោះ អាចបោះឆ្នោតតាមសំបុត្រក្នុងរដ្ឋកាលីហ្វ័រនីញ៉ាបាន។ សូមបំពេញក្រដាសដាក់ពាក្យសុំសន្លឹកឆ្នោតបោះឆ្នោត-តាម-សំបុត្រ នៅក្នុងកូនសៀវភៅគំរូសន្លឹកឆ្នោតរបស់អ្នក ឬរកវានៅ sos.ca.gov ឬទាក់ទងការិយាល័យបោះឆ្នោតខោនធី របស់អ្នក។ ក្រដាសដាក់ពាក្យសុំរបស់អ្នកដែលបានបំពេញចប់ ត្រូវតែមកដល់ការិយាល័យបោះឆ្នោតខោនធីរបស់អ្នក យ៉ាងតិចបំផុតប្រាំពីរថ្ងៃ មុនថ្ងៃបោះឆ្នោត។

ដើម្បីឲ្យប្រាកដថាសន្លឹកឆ្នោតដែលអ្នកបានបោះ បានមកដល់ទាន់កាលកំណត់ សន្លឹកឆ្នោតដែលអ្នកបានបោះ ត្រូវតែបានបោះតាប្រៃសណីយ៍នៅចំថ្ងៃ ឬនៅមុនថ្ងៃបោះឆ្នោត និងបានទទួល ដោយការិយាល័យបោះឆ្នោតខោនធីរបស់អ្នក មិនយឺតជាងបីថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោតឡើយ។

ការបោះឆ្នោតជាបណ្តោះអាសន្ន

ទោះបើឈ្មោះរបស់អ្នក ឥតមាននៅក្នុងបញ្ជីអ្នកបោះឆ្នោត នៅទីកន្លែងបោះឆ្នោត ក៏អ្នកមានសិទ្ធិបោះឆ្នោតបាន ជាមួយនឹងសន្លឹកឆ្នោតបណ្តោះអាសន្ន នៅក្នុងខោនធីដែលអ្នកបានចុះឈ្មោះបោះឆ្នោត។ សន្លឹកឆ្នោតបណ្តោះអាសន្នរបស់អ្នក នឹងបានរាប់តែបន្ទាប់ពីមន្ត្រីការបោះឆ្នោត បានបញ្ជាក់ថាអ្នកពិតជាអ្នកបោះឆ្នោតបានចុះឈ្មោះ ហើយអ្នកមិនបានបោះឆ្នោតនៅទីណាផ្សេងទៀត ក្នុងការបោះឆ្នោតនោះទេ។ បុគ្គលិកនៅកន្លែងបោះឆ្នោតអាចផ្តល់ព័ត៌មានឲ្យអ្នក អំពីរបៀបឆែកមើល បើសិនសន្លឹកឆ្នោតបណ្តោះអាសន្នរបស់អ្នក ត្រូវបានរាប់ និងបើវាមិនបានរាប់ ហើយនិងមូលហេតុអ្វី។

រកទីកន្លែងបោះឆ្នោតរបស់អ្នក

ទីកន្លែងបោះឆ្នោតរបស់អ្នក អាចនឹងផ្លាស់ប្តូរក្នុងចន្លោះពេលការបោះឆ្នោត។ សូមឆែកមើលខាងខ្លងនៃកូនសៀវភៅគំរូសន្លឹកឆ្នោតរបស់អ្នក សំរាប់ទីកន្លែងបោះឆ្នោតរបស់អ្នក។ អ្នកក៏អាចរកទីកន្លែងបោះឆ្នោតរបស់អ្នក ដោយទូរស័ព្ទទៅការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ឬលេខពិសេសអ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការ លេខ (888) 345-4917 ឬមើល sos.ca.gov។

ថ្ងៃទី 7 ខែមិថុនា | ការបោះឆ្នោត ប្រធានាធិបតីជាបឋម

ចុះឈ្មោះបោះឆ្នោត ឲ្យទាន់	**ថ្ងៃទី 23 ខែឧសភា**
ស្នើសុំសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ ឲ្យទាន់	**ថ្ងៃទី 31 ខែឧសភា**
ផ្ញើសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ ទៅវិញ (ត្រូវតែបានបោះត្រាប្រៃសណីយ៍ ឲ្យទាន់)	**ថ្ងៃទី 7 ខែមិថុនា**

ថ្ងៃទ 8 ខែវិច្ឆិកា | ការបោះឆ្នោតទូទៅ

ចុះឈ្មោះបោះឆ្នោត ឲ្យទាន់	**ថ្ងៃទី 24 ខែតុលា**
ស្នើសុំសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ ឲ្យទាន់	**ថ្ងៃទី 1 ខែវិច្ឆិកា**
ផ្ញើសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ ទៅវិញ (ត្រូវតែបានបោះត្រាប្រៃសណីយ៍ ឲ្យទាន់)	**ថ្ងៃទី 8 ខែវិច្ឆិកា**

ដើម្បីរកកន្លែងបោះឆ្នោតរបស់អ្នក

★ ★ ★ ★ ★

វាយពាក្យ *VOTE*

GOVOTE

RegisterToVote.ca.gov